ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តុលាការប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥៧៧

ចុះថ្ងៃទី : ១៨-១២-០២

សាលដីកា

លេខ : ២៥ "ខ"

ចុះថ្ងៃទី ២៣-០៣-០៦

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែមិនា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចខាងក្រោម

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោកស្រី [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥៧៧ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២ រវាង

១. ជនជាប់ចោទឈ្មោះ [redacted] ផា ហៅ ចក់ ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនចាប់ខ្លួន នៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង មុខរបរ រត់ម៉ូតូឌុប ប្រពន្ធឈ្មោះ ជា សុខា គ្មានកូន ឪពុកឈ្មោះ ម៉ី (ស) ម្ដាយឈ្មោះ ឃុន ហា (រ) ចាប់ខ្លួនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២។

២. ជនជាប់ចោទឈ្មោះ [redacted] **សុជីវ័ន** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនចាប់ខ្លួន វត្តរំដួល ឃុំវត្តរំដួល ស្រុកបាត់ដំបង ខេត្តបាត់ដំបង មុខរបរ សិស្ស នៅលីវ ឪពុកឈ្មោះ សោម សុវណ្ណ (រ) ម្ដាយឈ្មោះ គា ផារ៉ែន (រ) ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២។

<u>**ជាប់ចោទពីបទ**</u> " ធ្វើមនុស្សឃាតគិតទុកជាមុន " ប្រព្រឹត្តនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ០៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២។

៣. ជនជាប់ចោទឈ្មោះ [redacted] **សុខា** ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនចាប់ខ្លួន ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង [redacted] គ្មានកូន ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២។

៤. ជនជាប់ចោទឈ្មោះ [redacted] ពន្លឺ ភេទស្រី អាយុ ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនចាប់ខ្លួន ភូមិបល្ល័ង្កក្រោម [redacted] ស្រុកថ្មគោល ខេត្តបាត់ដំបង មុខរបរ ធ្វើស្រែ ប្ដីឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២។ ៥៣

**ជាប់ចោទពីបទ** ៖ សមគំនិតក្នុងអំពើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង

- ជនរងគ្រោះឈ្មោះ [redacted] ចន្ទ្រា ភេទស្រី អាយុ ១៤ឆ្នាំ (ស្លាប់)។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ របស់ឈ្មោះ [redacted] ជា. [redacted] ពន្នី. [redacted] សុខា និង [redacted] សុជីវ៉ន សុំប្តឹងឧទ្ធរណ៍ នឹងសាលក្រមលេខ ៥៦ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០២ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

**ដំណើររឿងដោយសង្ខេប**

កាលពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០២ វេលាម៉ោង១២ថ្ងៃត្រង់ ឈ្មោះ [redacted] ពន្នី បានហៅឈ្មោះ [redacted] ចន្ទ្រា មកលេង និង លខោអាវ ឈ្មោះ [redacted] ពន្នី បានអោយឈ្មោះ [redacted] ចន្ទ្រា ចូលទៅក្នុងផ្ទះ ឈ្មោះ [redacted] ពន្នី អោយឈ្មោះ [redacted] ចន្ទ្រា លខោអាវ ពេលលខោអាវរួច [redacted] ជា ក៏ស្ទុះទៅខ្ទប់មាត់ជនរងគ្រោះ ភ្លាមនោះឈ្មោះ [redacted] សុជីវ៉ន ក៏បានយកក្រមាទៅទាក់កឈ្មោះ [redacted] ចន្ទ្រា និង ចងដៃ ចងជើង រួចកន្ត្រាក់ក្រមាដែលទាក់កជនរងគ្រោះឡើងលើបណ្តោលអោយស្លាប់។

- បានឃើញសាលក្រមលេខ ៥៦ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ

I. **អំពីទណ្ឌកម្ម**

- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះដូចខាងក្រោម

ក. ជនជាប់ចោទឈ្មោះ [redacted] ជា ហៅ ចក់ ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារតម្រូវអោយធ្វើការកំណត់ ២០ឆ្នាំ (ម្ភៃឆ្នាំគត់) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២ តទៅ

ខ. ជនជាប់ចោទឈ្មោះ [redacted] សុជីវ៉ន ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១០ឆ្នាំ (ដប់ឆ្នាំគត់) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២ តទៅ

ពីបទ ៖ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រាទី ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ និង តាមមាត្រាទី ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា។

គ. ជនជាប់ចោទឈ្មោះ [redacted] ពន្នី ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារតម្រូវអោយធ្វើការកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំគត់) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២ តទៅ។

ឃ. ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទស្រី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារតម្រូវអោយធ្វើការកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំគត់) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២ តទៅ។

ពីបទ សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០២។ល

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រាទី ៦៩នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា និង តាមមាត្រាទី ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ នស/រកម/០០៤។

II. **អំពីសំណងរដ្ឋប្បវេណី**

ក. ទទួលពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឪពុកជនរងគ្រោះ នៅចំពោះមុខតុលាការនាពេលសវនាការ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់

ខ. បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]ជា, [redacted] សុខា, [redacted] ពន្លឺ រួមជាមួយឪពុកម្តាយជនជាប់ចោទឈ្មោះ [redacted] សុជីវិន រួមគ្នាសងសំណងរដ្ឋប្បវេណី ចំនួន ២០ ០០០ ០០០រៀល (ម្ភៃលានរៀលគត់) ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សុខ សុផល។ សំណូមពរលើសពីនេះ ត្រូវបដិសេធចោល។

III. ពេលសាលក្រមចូលជាស្ថាពរហើយ បើជនជាប់ចោទឈ្មោះ [redacted] ជា, [redacted] សុខា និង[redacted]ពន្លឺ រឹងរូសពុំព្រមបង់ជម្ងឺចិត្តចំនួន ២០ លានរៀល( ម្ភៃលានរៀល) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល ទេនោះត្រូវដាក់គុកបង្ខំដល់រូបកាយ ចំនួន០២ឆ្នាំគត់បន្ថែមទៀត ដើម្បីបង្ខំទារប្រាក់ធនទណ្ឌតាមមាត្រាទី ០៧ និង ទី០៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១៨ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា។

IV. **វត្ថុតាងដូចខាងក្រោមនេះ**

១. រឹបអូសប្រាក់ធានាសំណង ៥ ០០០បាត ដែលតម្កល់ទុកនៅតុលាការ កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ប្រគល់អោយឈ្មោះ សុខ សុផល ជាដើមបណ្តឹងរដ្ឋប្បវេណី។

២. រឹបអូសម៉ូតូ C 100 ពណ៌ក្រហម សេរីចាស់ចំនួន ០១គ្រឿងដែលជាកម្មសិទ្ធរបស់ជនជាប់ចោទឈ្មោះ [redacted] ជា ដែលរក្សាទុកជាបណ្តោះអាសន្ននៅស្នងការនគរបាលខេត្តបាត់ដំបង លក់ឡាយឡុងទូទាត់ក្នុងសំណង អោយទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ[redacted] សុផល។

៣. ផង់ពណ៌លឿងចំនួន ០១ ( មានដុំថ្ម មើមរុក្ខជាតិ និង យន្តក្រដាស់) ផង់ផ្លាស្ទិចតូច ស្បែកជើងជ័រចំនួន ០១គូ ខ្សែកអង្កាំជ័រ ០១ខ្សែ ស្លឹកដង្កោក្រៀម ១០សន្លឹក និង បន្ទះឫស្សីមួយកំណាត់ ត្រូវរឹបអូសនិងបំផ្លាញចោល។

V. សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឪពុកម្តាយជនជាប់ចោទឈ្មោះ យុន ជា ដើមបណ្តឹងរដ្ឋប្បវេណី និង កំបាំងមុខឪពុកម្តាយជនជាប់ចោទឈ្មោះ[redacted]សុជីវិន បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ របស់ឈ្មោះ [redacted] ជា, [redacted] ពន្លឺ, [redacted] សុខា និង [redacted] សុជីវិន សុំប្តឹង ឧទ្ធរណ៍ និងសាលក្រមលេខ ៥៦ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០២ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចសេចក្តីសំរេចទាំងមូល
- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍
- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

**ឥឡូវសាវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុជូនអង្គសវនាការ

ប្រធានក្រុមប្រឹក្សាអោយក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយនៅតុលាការខេត្តបាត់ដំបង។

ប្រធានក្រុមប្រឹក្សាអោយក្រឡាបញ្ជីអានចម្លើយរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានឆ្លើយនៅតុលាការខេត្តបាត់ដំបង។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

១. បណ្តឹងឧទ្ធរណ៍លេខ ១២៤ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ របស់ឈ្មោះ [redacted] ជា ហៅ ចក់, [redacted] ពន្លឺ, [redacted] សុខា និង [redacted] សុជីវីន ទុកជាត្រឹមត្រូវតាមគតិច្បាប់។

២. តម្កល់សាលក្រមលេខ ៥៦ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០២ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការ។

**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា**

១. បណ្តឹងឧទ្ធរណ៍លេខ ១២៤ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០០២ របស់ជនជាប់ចោទឈ្មោះ [redacted] ជា ហៅ ចក់, [redacted] ពន្លឺ, [redacted] សុខា និង [redacted] សុជីវីន ធ្វើឡើងនៅក្នុងកំណត់ច្បាប់។

២. ជនជាប់ចោទឈ្មោះ [redacted] ជា ហៅ ចក់ និង ឈ្មោះ [redacted] សុជីវីន ថាខ្លួនពិតជាបានសម្លាប់ជនរងគ្រោះឈ្មោះ [redacted] ចន្ទ្រា ពិតប្រាកដមែន ដោយមុននឹងសម្លាប់ ខ្លួនបានរៀបចំគំរោងផែនការទុកជាមុន ដូចជាជីករណ្តៅទុក ប្រើល្បិចហៅជនរងគ្រោះអោយចូលទៅផ្ទះខ្លួន ដោយកុហកថាអោយលខោអាវជាដើម រួចយកក្រមារឹតកជនរងគ្រោះរហូតដល់ស្លាប់ ហើយពេលយប់ទើបយកទៅកប់នៅរណ្តៅដែលបានជីកទុកជាស្រេចនោះ ឯជនជាប់ចោទឈ្មោះ [redacted] ពន្លឺ ថាមិនបានជួយចាត់ចែងទេ តែខ្លួនគ្មានសាក្សីសំអាងឡើយ ចំណែកជនជាប់ចោទឈ្មោះ [redacted] សុខា ថាក្រោយមកទើបខ្លួនដឹងថាប្តីខ្លួនសម្លាប់ជនរងគ្រោះ ខ្លួនរួមដំណើរជិះម៉ូតូទៅប៉ោយប៉ែតមែន។

៣. តុលាការជាន់ទាបបានលើកសំអាងហេតុត្រឹមត្រូវសព្វគ្រប់ និង ច្បាស់លាស់ ព្រមទាំងបានបញ្ជាក់ថាក្នុងការសម្លាប់ជនរងគ្រោះនេះ ជនជាប់ចោទទាំង០៤នាក់ ពិតជាបានរួមសហការផ្តល់មធ្យោបាយ ដើម្បីសម្លាប់ រហូតដល់បានសម្រេច, សាលាឧទ្ធរណ៍យល់ស្របនឹងសំអាងហេតុនោះ ដូច្នេះមិនចាំបាច់លើកយកសំអាងហេតុដដែលនោះ មកសរសេរឡើងវិញទៀតទេ

៤. សាលក្រមព្រហ្មទណ្ឌលេខ ៥៦ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្តបាត់ដំបង សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២៤ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០០២ របស់ជនជាប់ចោទឈ្មោះ [redacted] ជា ហៅ ចក់, [redacted] ពន្លឺ, [redacted] សុខា និង [redacted] សុជីវីន្ទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៦ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការ ពេញទាំងមូល៖

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ចំពោះមុខមេធាវីការពារជនជាប់ចោទ, និងដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ, ប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៦ កំបាំងមុខមេធាវីការពារជនជាប់ចោទ, ដើមបណ្ដឹងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ, កំបាំងមុខជនជាប់ចោទ។

បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់។

សាលដីកានេះចូលជាស្ថាពរ មានអានុភាពអនុវត្តតែលើឈ្មោះ [redacted] ជា ហៅ ចក់ ក្រៅពីនោះ ពុំមានអានុភាពអនុវត្តឡើយ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.......................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]